# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ ១៦០៨ អ.ក
ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១
សាលក្រមលេខ ១១៩ ស.ព្រ.ណ/២៣
ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល ។
កាលបរិច្ឆេទសវនាការ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ និង ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ។
កាលបរិច្ឆេទការប្រកាសសាលក្រមថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ ។

### ចៅក្រមជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង

### ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១៦០៨ អ.ក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

១. ឈ្មោះ [redacted] ដេត ភេទស្រី អាយុ ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរធ្វើការរោងចក្រ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និង ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] កង (ស្លាប់) ម្តាយឈ្មោះ [redacted] សឿន (ស្លាប់) នៅលីវ ជា**អនីតិជន** ។ (ក្រៅឃុំ)

២. ឈ្មោះ [redacted] សេងហ៊ី ភេទប្រុស អាយុ ២៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តបាត់ដំបង និង ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ហាន់ (រស់) ម្តាយឈ្មោះ [redacted] ព្រៃ (រស់) ប្រពន្ធឈ្មោះ [redacted] ដាវ (រស់) មានកូន ០១នាក់ ជានីតិជន ។ (ក្នុងឃុំ) (ឃាត់ខ្លួននៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣)



Scanned with CamScanner

៣. ឈ្មោះ [redacted] ដាវ ភេទស្រី អាយុ ១៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និង ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកម្តាយ (មិនត្រូវបានគេស្គាល់) ប្តីឈ្មោះ [redacted] សេងហ៊ មានកូន ០១នាក់ ជានីតិជន ។ (ក្រៅឃុំ)

៤. ឈ្មោះ [redacted] ធា ភេទប្រុស អាយុ ២២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តពោធិ៍សាត់ និង ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ធី (ស្លាប់) ម្តាយឈ្មោះ [redacted] សោភ័ណ្ឌ (ស្លាប់) ប្រពន្ធឈ្មោះ [redacted] ខឿន (រស់) មានកូន ០១នាក់ ជានីតិជន ។ (ក្នុងឃុំ) (ឃាត់ខ្លួននៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣)

៥. ឈ្មោះ [redacted] ខឿន ភេទស្រី អាយុ ១៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និង ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកម្តាយ (មិនត្រូវបានគេស្គាល់) ប្តីឈ្មោះ [redacted] ធា មានកូន០១នាក់ ជានីតិជន ។ (ក្រៅឃុំ)

ត្រូវបានជាប់ចោទពី **បទហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីខែឧសភា ឆ្នាំ២០២១ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២៤៨ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ដាវ ។
មានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ដេត ។
មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ឈ្មោះ [redacted] ដេត ឈ្មោះ [redacted] សេងហ៊ ឈ្មោះ [redacted] ដាវ ឈ្មោះ [redacted] ធា ឈ្មោះ [redacted] ខឿន ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាបាន ភេទប្រុស អាយុ ៥៧ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

- **បានឃើញ** ដីកាដំណោះស្រាយលេខ ៦១៣ "ឌ"/២៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ ។

## អង្គហេតុដែលបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះ

នៅក្នុងអំឡុងឆ្នាំ២០២១ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាបាន ភេទប្រុស អាយុ ៥៧ឆ្នាំ បានទិញដីមួយ កន្លែងពីឈ្មោះ [redacted] សុរភី ភេទស្រី អាយុ ៣១ឆ្នាំ ដីមានទីតាំងស្ថិតនៅភូមិព្រែកតាព្រីង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល (បច្ចុប្បន្នភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល ) សរុបទំហំ ៧.១៧៥ (ប្រាំពីរពាន់ មួយរយចិតសិបប្រាំ) ម៉ែត្រការ៉េ ។ នៅអំឡុងឆ្នាំ២០១៩ មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តកណ្តាល បានចុះធ្វើប្លង់ជាប្រព័ន្ធ (វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) ។ ក្រោយពេលមន្ត្រីជំនាញបាន ធ្វើការវាស់វែងកាត់ចំណីផ្លូវរួចរាល់ហើយនៅក្នុងឆ្នាំ២០០៩ ខាងមន្ទីរបានចេញវិញ្ញាបនបត្រ



Scanned with CamScanner

សម្គាល់ម្ចាស់អចលនវត្ថុ ០៨១០១១០១-០៨៦៨ ឱ្យដើមបណ្តឹងរដ្ឋប្បវេណី ដោយដីនៅសល់ទំហំសរុបតែ ៥.១០៤ (ប្រាំពាន់មួយរយបួន) ម៉ែត្រការ៉េ ហើយដើមបណ្តឹងរដ្ឋប្បវេណី បានកាន់កាប់ និង គ្រប់គ្រងដីនេះ រហូតមកដល់សព្វថ្ងៃ ។ ស្រាប់តែនៅអំឡុងខែឧសភា ឆ្នាំ២០២១ មានជនជាប់ចោទទាំង ០៥នាក់ ដែលមាន ឈ្មោះ [redacted] **ដេត** ភេទស្រី អាយុ ១៧ឆ្នាំ ឈ្មោះ [redacted] **សេងហ៊ី** ភេទប្រុស អាយុ ២១ឆ្នាំ ឈ្មោះ [redacted] **ដាវ** ភេទស្រី អាយុ ១៩ឆ្នាំ ឈ្មោះ [redacted] **ធា** ភេទប្រុស អាយុ ២០ឆ្នាំ និង ឈ្មោះ [redacted] **ឌឿន** ភេទស្រី អាយុ ១៩ឆ្នាំ បានមក រំលោភសាងសង់ផ្ទះចំនួន ៣ខ្នង នៅលើដីដែលជាកម្មសិទ្ធិស្របច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ។

## ដំណើរការនៃកិច្ចពិភាក្សាដេញដោល

១. ជនជាប់ចោទឈ្មោះ [redacted] **សេងហ៊ី** បានឆ្លើយនៅចំពោះមុខតុលាការថា ៖ ខ្ញុំបាទមិនស្គាល់ឈ្មោះ [redacted] **សាបាន** ដែលជាអ្នកប្តឹងខ្ញុំនោះទេ ។ ខ្ញុំបានមករស់នៅផ្ទះខាងប្រពន្ធខ្ញុំ ឈ្មោះ [redacted] **ដាវ** មានទីតាំងស្ថិតនៅភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល នៅក្នុងអំឡុងឆ្នាំ២០១៩ ខ្ញុំមិនដឹងថា ផ្ទះនេះធ្វើនៅក្នុងឆ្នាំណាទេ ហើយពេលខ្ញុំមកនៅផ្ទះនេះគឺ មានស្រាប់ហើយ ។ ដីនេះ មានទំហំ ៧ម៉ែត្រ គុណនឹង ៣០ម៉ែត្រ ។ ផ្ទះដែលខ្ញុំរស់នៅធ្វើពីឈើប្រក់ស័ង្កសី ជញ្ជាំងស័ង្កសី មានទំហំ ៧ម៉ែត្រ គុណ នឹង ៦ម៉ែត្រ ផ្ទះនេះខ្ញុំរស់នៅបីនាក់ ប្រពន្ធខ្ញុំ និង កូនខ្ញុំ ។ ពួកខ្ញុំមករស់នៅ លើដីនោះ ដោយសារម្តាយក្មេកខ្ញុំឱ្យមករស់នៅ ដោយម្តាយក្មេកខ្ញុំប្រាប់ថា ដីនោះជាដីរបស់គាត់ ដែលរដ្ឋចែកឱ្យ គាត់មិនបានប្រាប់ថាដីដែលចែកឱ្យនោះគឺក្នុងឆ្នាំណានោះទេ ។ ហើយខ្ញុំមិនបានដឹង ថាម្តាយក្មេកខ្ញុំមានឯកសារអ្វីដែលបញ្ជាក់ថាជាគាត់ម្ចាស់ដីនោះទេ ។ ខ្ញុំមករស់នៅលើដីនោះប្រហែល ៤ឆ្នាំហើយ មិនមានអ្នកណាម្នាក់មកដេញពួកខ្ញុំទេ ។ ម្តាយក្មេកខ្ញុំមិនបានរស់នៅលើដីនោះទេ គាត់រស់នៅផ្ទះផ្សេងដែលក្បែរនោះ ។ បច្ចុប្បន្ន ពុំមាននរណាម្នាក់រស់នៅលើដី នោះទេ ។

២. ជនជាប់ចោទឈ្មោះ [redacted] **ធា** បានឆ្លើយនៅចំពោះមុខតុលាការថា ៖ ខ្ញុំបាទមករស់នៅផ្ទះខាងប្រពន្ធខ្ញុំ ឈ្មោះ [redacted] **ឌឿន** មានទីតាំងស្ថិតនៅផ្ទះនេះមានស្រាប់ហើយ ។ ដីនេះមានទំហំ ៦ម៉ែត្រ គុណនឹង ៣០ ម៉ែត្រ ។ ខ្ញុំរស់នៅពោធិ៍សាត់ ពេលខ្ញុំការប្រពន្ធរួច ខ្ញុំមករស់នៅខាងផ្ទះម្តាយក្មេក ។ ម្តាយក្មេកខ្ញុំឈ្មោះ សឿន (មិនស្គាល់ត្រកូល) ដីដែលបានសាងសង់ ផ្ទះនោះគឺនៅភូមិព្រែកតាព្រីង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល ។ ខ្ញុំមករស់នៅក្នុងឆ្នាំ២០១៩ ខ្ញុំមិនមានឯកសារអ្វីនោះទេ ខ្ញុំមករស់នៅខាងម្តាយក្មេកខ្ញុំ ដោយសារម្តាយក្មេកខ្ញុំឱ្យមករស់នៅ ។ ខ្ញុំមិនបានដឹងថាដីនោះជាដី របស់អ្នកដទៃទេ ។ ផ្ទះដែលបានសាងសង់នៅលើនោះ សព្វថ្ងៃមិនមានអ្នករស់នៅទេ ។

៣. សាក្សីឈ្មោះ [redacted] **សឿន** បានឆ្លើយនៅចំពោះមុខតុលាការថា ៖ខ្ញុំឈ្មោះ [redacted] **សឿន** ខ្ញុំជា ម្តាយក្មេករបស់ឈ្មោះ [redacted] **ធា** និង ឈ្មោះ [redacted] **សេងហ៊ី** ចំពោះឈ្មោះ [redacted] **ឌឿន** ឈ្មោះ [redacted] **ដេត** ឈ្មោះ [redacted] **ដាវ** ជាកូនបង្កើតរបស់ខ្ញុំ ។ ខ្ញុំមិនស្គាល់ម្ចាស់ដីដែលប្តឹងនោះទេ ។ ផ្ទះស័ង្កសី ៣ខ្នងនោះ គឺខ្ញុំជាអ្នកសង់ឱ្យកូនៗ ។ ពេលដែលសង់នោះ គឺខ្ញុំរកគេឱ្យជួយ។ ផ្ទះទាំងនោះគឺសង់យូរហើយ ។ ខ្ញុំរស់នៅដីនោះជាង២០ឆ្នាំ តែខ្ញុំមិនមានឯកសារកាន់កាប់ដីអ្វីនោះទេ ប៉ុន្តែមានមេឃុំ មេភូមិ បានដឹងថាខ្ញុំរស់នៅលើដីនោះជាង២០ឆ្នាំហើយ ។ ដីនោះខ្ញុំបានសាងសង់ផ្ទះ ពេលនោះមិនមាន អាជ្ញាធរមកប្រាប់នោះទេ ។ ពេលសាងសង់ គឺមានកូនៗខ្ញុំរស់នៅ ខ្ញុំក៏រស់នៅលើដីនោះដែរ។ កាលដែលការកូននោះគឺផ្ទះបានសាងសង់រួចហើយ ។ កាលការកូនទាំងពីរនាក់នោះ គឺម្នាក់ការ



Scanned with CamScanner

នៅខេត្តពោធិ៍សាត់ និង ម្នាក់ទៀតការនៅខេត្តបាត់ដំបង ។ ពេលមានដីកាតុលាការកោះហៅពួកកូនប្រសារខ្ញុំបានដឹង តែមកមិនទាន់ នាំឱ្យមិនបានសាកសួរអ្វីទេ ។ មកតែកូនៗមកតាមការកោះហៅរបស់តុលាការ ចំណែកខ្ញុំមិនបានមកទេ ។ ខ្ញុំជាអ្នកឱ្យកូនៗមករស់នៅក្នុងផ្ទះដែលសាងសង់លើដីនោះ ។ ម្ចាស់ដីឱ្យខ្ញុំរុះរើផ្ទះនៅលើដីនោះ ទើបខ្ញុំរុះរើចេញ ។ ខ្ញុំបានរុះរើផ្ទះលើដីនោះហើយ ។ ពួកខ្ញុំយល់ព្រមចេញពីផ្ទះនោះហើយ បច្ចុប្បន្នពុំមានអ្នកណារស់នៅលើដីនោះទៀតទេ ។ នៅក្នុងឆ្នាំខ្ញុំមិនចាំ មានអាជ្ញាធរសុរិយាដីចុះមកចែកដីឱ្យខ្ញុំ និង កូនៗខ្ញុំម្នាក់ ៣៥ ម៉ែត្រ ។ ពីមុនធ្វើផ្ទះនោះខ្ញុំធ្លាប់ដាំបន្លែនៅក្នុងឆ្នាំមិនចាំឆ្នាំទេ ប៉ុន្តែដាំតាំងពីប្តីខ្ញុំនៅរស់ ឥលូវប្តី ខ្ញុំស្លាប់ជាង៧ឆ្នាំហើយ ។ ខ្ញុំធ្លាប់ដាំបន្លែជិត២០ឆ្នាំហើយ ។ ពេលខ្ញុំធ្វើផ្ទះនោះ មានឈ្មោះ [redacted] សុវារី ប្រាប់ខ្ញុំថាមិចបានមកធ្វើផ្ទះនៅទីនេះ ។ ខ្ញុំចូលមកនៅផ្ទះនោះជាង២១ឆ្នាំហើយ ។ ពេលខ្ញុំធ្វើផ្ទះ ប្រហែល ៦ ទៅ ៧ឆ្នាំហើយ ។ ខ្ញុំធ្លាប់មានផ្ទះនៅលើទំនប់ គឺផ្ទះប្រក់ស័ង្កសី ។ ខ្ញុំធ្វើផ្ទះខ្ទមនោះ គឺ មានរយៈពេល ២០ឆ្នាំ ហើយ ។ ខ្ញុំមករស់នៅលើដីនោះ គឺខ្ញុំមិនចង់បានដីនោះទេ ប៉ុន្តែចង់បានសំណងពីរដ្ឋបន្តិចបន្តួចប៉ុណ្ណោះ ។

៤. អំណានចម្លើយ និង ពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាបាន (សង្ខេប) ៖ កាលពីថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៧ ខ្ញុំបាទបានទិញដីមួយកន្លែងពីឈ្មោះ [redacted] សុរភី ភេទស្រី អាយុ ៣១ឆ្នាំ ទីលំនៅសង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដីមានទីតាំងស្ថិតនៅភូមិព្រែកតាព្រីង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល (បច្ចុប្បន្នភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល) សរុបទំហំ ៧.១៧៥ (ប្រាំពីរពាន់មួយរយចិតសិតប្រាំ) ម៉ែត្រការ៉េ ។ នៅក្នុងអំឡុងឆ្នាំ២០០៩ មន្ទីរ រៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តកណ្តាល បានចុះធ្វើប្លង់ជាប្រព័ន្ធ (វិញ្ញាបនបត្រ សម្គាល់ម្ចាស់អចលនវត្ថុ) ។ ក្រោយពេលមន្ត្រីជំនាញគាត់ចំណីផ្លូវរួចរាល់ហើយ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ខាងមន្ទីរបានចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១០១១០១-០៨៦៨ ឱ្យខ្ញុំបាទ ដោយដីរបស់ខ្ញុំបាទនៅសល់ទំហំសរុបតែ ៥.១០៤ (ប្រាំពាន់ មួយរយបួន) ម៉ែត្រការ៉េ ។ អំឡុងពេលនីតិវិធីនៃការកសាងប័ណ្ណ ខ្ញុំបាទមានភារកិច្ចនៅខេត្តព្រះវិហារ ខ្ញុំបាទមិនសូវដែល បានទៅមើលថែរទាំដី និង ម្យ៉ាងខ្ញុំបាទសំអាងថាដីរបស់ខ្ញុំបាទ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រឹមត្រូវតាមច្បាប់ ពុំអាចបុគ្គលណារំលោភបានឡើយ ។ ស្រាប់នៅអំឡុងខែឧសភា ឆ្នាំ២០២១ ជនល្មើសទាំ០៣គ្រួសារ ដែលមានឈ្មោះ [redacted] ដេត ឈ្មោះ [redacted] សេងហ៊ី ឈ្មោះ [redacted] ដាវ ឈ្មោះ [redacted] ធា និង ឈ្មោះ [redacted] ឌឿន បានមករំលោភសាងសង់ផ្ទះ ចំនួន ៣ខ្នង នៅលើដីដែលជាកម្មសិទ្ធិស្របច្បាប់របស់ខ្ញុំបាទ។ ខ្ញុំទាមទារសំណងជម្ងឺចិត្តជាប្រាក់ក្នុងមួយគ្រួសារ ចំនួន ២០.០០០(ពីរម៉ឺន) ដុល្លារអាមេរិក ។

៥. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ៖ ជនជាប់ចោទឈ្មោះ [redacted] ដាវ ឈ្មោះ [redacted] ឌឿន និង ជនជាប់ចោទឈ្មោះ [redacted] ដេត អវត្តមាន គ្រប់ដំណាក់កាលតុលាការ ។ ជនជាប់ចោទបានសារភាពថាពិតជាបានចូលមករស់នៅលើដីនោះពិតប្រាកដមែន តាមការប្រាប់របស់ម្តាយក្មេកឱ្យមកចូលរស់នៅ ប៉ុន្តែពុំមានឯកសារណាមួយបញ្ជាក់ថាដីនោះជាកម្មសិទ្ធិរបស់ខ្លួន និង ពុំមានឯកសារណាមួយបញ្ជាក់ថាខ្លួនបានចូលមកកាន់កាប់ដីនោះមានរយៈពេលជាង ២០(ម្ភៃ) ឆ្នាំ នោះទេ ដែលនេះគ្រាន់តែជាការអះអាងរបស់ខ្លួន ពុំមានភស្តុតាងណាមួយបញ្ជាក់នោះទេ តំណាងអយ្យការ



Scanned with CamScanner

ស្នើសុំរក្សាការចោទប្រកាន់លើជនជាប់ចោទ ដដែល និង ប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៦. សេចក្តីសន្និដ្ឋានការពាររបស់លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ៖ កូនក្តីមិនបានប្រព្រឹត្តដូចចោទប្រកាន់នោះទេ ។ ដោយសារឈ្មោះម្ចាស់ដីដើមដែលអះអាងថាជាម្ចាស់ដីនោះ គឺគាត់មិនមែនជាភោគីស្របច្បាប់ ។ ម្យ៉ាងវិញទៀត ឯកសារដែលធ្វើឡើងគឺខុសពីទម្រង់ភូមិឃុំ គឺអាចនិយាយបានថាឯកសារនោះជាឯកសារក្លែង ។ កំឡុងពេលដែលសាក្សីឈ្មោះ [redacted] សឿន បានមករស់នៅ គឺមានការទទួលស្គាល់ពីអាជ្ញាធរភូមិឃុំ ។ ឈ្មោះ [redacted] ភារី មិនមានវត្តមាននៅលើដីនោះ ។ ភោគីស្របច្បាប់ឈ្មោះ [redacted] សឿន ព្រោះគាត់អាស្រ័យផលមុនឆ្នាំ២០០១ ។ កូនក្តីខ្ញុំបាទជាមនុស្សល្អនៅក្នុងសង្គម មិនធ្លាប់មានរឿងអាស្រូវ មិនធ្លាប់មានរឿងក្នុងតុលាការ មានការកោះហៅតុលាការ គាត់បានចូលរួមគ្រប់ដំណាក់កាល ។ ដើមបណ្តឹងមិនមាន ភស្តុតាងគ្រប់គ្រាន់ ។ ខ្ញុំបាទតំណាងឱ្យកូនក្តីខ្ញុំ មេត្តាលើកលែងបទចោទប្រកាន់លើកូនក្តីខ្ញុំបាទទាំងពីរនាក់ដើម្បីអាចឱ្យគាត់ចូលរួមរស់នៅក្នុងសង្គម និង ជួបជុំគ្រួសារគាត់វិញ ។

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាងលើសំណុំរឿងនេះ

## សំអាងហេតុ

១. ក្រោយពីបានធ្វើការពិភាក្សាដេញដោល ស្តាប់អំណានចម្លើយដើមបណ្តឹង ចម្លើយសក្សី សួរចម្លើយជនជាប់ចោទ ព្រមទាំងពិនិត្យឯកសារភស្តុតាងផ្សេងៗ អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] **ដេត** ឈ្មោះ [redacted] **សេងហ៊ី** ឈ្មោះ [redacted] **ធា** ឈ្មោះ [redacted] **ដាវ** ឈ្មោះ [redacted] **ឡឿន** បានចូលទៅកាន់កាប់ដីស្ថិតនៅភូមិព្រែកតាព្រីង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល (បច្ចុប្បន្នភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល) ទាំងដែលខ្លួនដឹងថាពុំមែនជាម្ចាស់កម្មសិទ្ធិស្របច្បាប់នៅលើដី១កន្លែងនោះ ។ ដូចនេះតុលាការជឿជាក់ថា ជនជាប់ចោទ ពិតជាបានប្រព្រឹត្ត **បទប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ពិតប្រាកដមែន ដោយមានចម្លើយ និង ភស្តុតាងស៊ីចង្វាក់គ្នា ។

២. ជនជាប់ចោទឈ្មោះ [redacted] **សេងហ៊ី** ភេទប្រុស អាយុ ២១ឆ្នាំ ឈ្មោះ [redacted] **ធា** ភេទប្រុស អាយុ ២២ឆ្នាំ ឈ្មោះ [redacted] **ដាវ** ភេទស្រី អាយុ ១៩ឆ្នាំ និង ឈ្មោះ [redacted] **ឡឿន** ភេទស្រី អាយុ ១៩ឆ្នាំ ជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] **ដេត** ភេទស្រី អាយុ ១៧ឆ្នាំ ជា**អនីតិជន** ក៏ពិតមែន ក៏ប៉ុន្តែជនជាប់ចោទអាចពិចារណា និងយល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន ហើយលក្ខខណ្ឌគតិយុត្តិតម្រូវឱ្យទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និង ត្រូវបានច្បាប់កំណត់ទុកជាបទល្មើសព្រហ្មទណ្ឌ យោង



Scanned with CamScanner

តាមបញ្ញត្តិនៃមាត្រា ៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប៉ុន្តែមូលទោសត្រូវបានបន្ថយពាក់កណ្តាល យោងមាត្រា ១៦០ នៃ ក្រមព្រហ្មទណ្ឌ។

៣. ជនជាប់ចោទបានដឹងយ៉ាងច្បាស់ថាសកម្មភាពរបស់ខ្លួនជាអំពើរំលោភបំពាន និង ប៉ះពាល់ដល់កម្មសិទ្ធិ និង សិទ្ធិស្របច្បាប់របស់អ្នកដទៃជាអំពើខុសច្បាប់ តែខ្លួននៅតែប្រព្រឹត្ត ។ ដូចនេះតុលាការយល់ឃើញថាជនជាប់ចោទ មានចេតនាក្នុងការប្រព្រឹត្តបទល្មើស ។

៤. តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំរក្សាបទចោទប្រកាន់ដដែល និង តុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទ ។ តុលាការនឹងពិចារណាសម្រេចស្រប តាមអង្គហេតុ និង អង្គច្បាប់។

៥. សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានស្នើសុំតុលាការ សម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ទាំងស្រុង ។ តុលាការយល់ឃើញថា ការស្នើសុំរបស់មេធាវីមិនត្រឹមត្រូវនោះទេ ដោយមូលហេតុដូចមានក្នុងសំអាងហេតុ ខាងលើ ។

៦. ក្រោយពីឆ្លងកាត់ការពិភាក្សាដេញដោល និង ពិនិត្យភស្តុតាងនានា តុលាការយល់ឃើញថា ជនជាប់ចោទ ឈ្មោះ [redacted] **សេងហ៊ី** ភេទប្រុស អាយុ ២១ឆ្នាំ ឈ្មោះ [redacted] **ធា** ភេទប្រុស អាយុ ២២ឆ្នាំ ឈ្មោះ [redacted] **ដាវ** ភេទស្រី អាយុ ១៩ឆ្នាំ ឈ្មោះ [redacted] **ឌឿន** ភេទស្រី អាយុ ១៩ឆ្នាំ និង ឈ្មោះ [redacted] **ដេត** ភេទស្រី អាយុ ១៧ឆ្នាំ បានប្រព្រឹត្ត **បទប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីខែឧសភា ឆ្នាំ២០២១ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២៤៨ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

៦. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាបាន** បានប្តឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ក្នុងមួយគ្រួសារ ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក ចំនួន ៣គ្រួសារ សរុបចំនួន ៦០.០០០ (ប្រាំមួយម៉ឺន) ដុល្លាអាមេរិក តុលាការនឹងពិចារណាសម្រេចក្នុងកម្រិតសមរម្យ ។

៧. ជនជាប់ចោទឈ្មោះ [redacted] **ដេត** ភេទស្រី អាយុ ១៧ឆ្នាំ នាំឱ្យតុលាការសម្រេចផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោស

ក. ឈ្មោះ [redacted] **សេងហ៊ី** ភេទប្រុស អាយុ ២១ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ

ខ. ឈ្មោះ [redacted] **ធា** ភេទប្រុស អាយុ ២២ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ

គ. ឈ្មោះ [redacted] **ដេត** ភេទស្រី អាយុ ១៧ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ខែ



Scanned with CamScanner

ឃ. ឈ្មោះ [redacted] ដាវ ភេទស្រី អាយុ ១៩ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ

ង. ឈ្មោះ [redacted] ឌឿន ភេទស្រី អាយុ ១៩ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ

ពី **បទប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីខែឧសភា ឆ្នាំ២០២១ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសស្របតាមបញ្ញត្តិមាត្រា ២៤៨ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

២. បង្គាប់ឱ្យជនជាប់ចោទ

ក. ឈ្មោះ [redacted] **សេងហ៊ា** ភេទប្រុស អាយុ ២១ឆ្នាំ (សាវតាជាតិខាងលើ)

ខ. ឈ្មោះ [redacted] **ធា** ភេទប្រុស អាយុ ២២ឆ្នាំ (សាវតាជាតិខាងលើ)

គ. ឈ្មោះ [redacted] **ដេត** ភេទស្រី អាយុ ១៧ឆ្នាំ (សាវតាជាតិខាងលើ)

ឃ. ឈ្មោះ [redacted] **ដាវ** ភេទស្រី អាយុ ១៩ឆ្នាំ (សាវតាជាតិខាងលើ)

ង. ឈ្មោះ [redacted] **ឌឿន** ភេទស្រី អាយុ ១៩ឆ្នាំ (សាវតាជាតិខាងលើ)

រួមគ្នាសងសំណង ចំនួន ១០ (ដប់) លានរៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាបាន** ភេទប្រុស អាយុ ៥៧ឆ្នាំ ។

សាលក្រមនេះ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សេងហ៊ា** ឈ្មោះ [redacted] **ធា** កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **ដេត** ឈ្មោះ [redacted] **ដាវ** ឈ្មោះ [redacted] **ឌឿន** និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាបាន** ។ ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ តាមនីតិវិធីច្បាប់ ។

ថ្ងៃពុធ ៥ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កណ្តាល, ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៥ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កណ្តាល, ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner